# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៥៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/ ៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គ.ជ.ប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តពោធិ៍សាត់ ក្នុងអាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ឆាយ សារ៉េត ជាប្រធានក្រុមប្រឹក្សាខេត្ត

២- ឯកឧត្តម ឈុន សុខ ជាសមាជិកក្រុមប្រឹក្សាខេត្ត

៣- ឯកឧត្តម កែម ធី ជាសមាជិកក្រុមប្រឹក្សាខេត្ត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- ឯកឧត្តម ឆី គីមតុក ជាសមាជិកក្រុមប្រឹក្សាខេត្ត

៥- ឯកឧត្តម ឆាយ លីមអៀង ជាសមាជិកក្រុមប្រឹក្សាខេត្ត

៦- ឯកឧត្តម ខឡូ សំអុល ជាសមាជិកក្រុមប្រឹក្សាខេត្ត

៧- ឯកឧត្តម ម៉េង សោភ័ណ្ឌ ជាសមាជិកក្រុមប្រឹក្សាខេត្ត

៨- ឯកឧត្តម ចាប សារឿង ជាសមាជិកក្រុមប្រឹក្សាខេត្ត

៩- លោកជំទាវ ហួន សារ៉ាន ជាសមាជិកក្រុមប្រឹក្សាខេត្ត

១០- ឯកឧត្តម មាស ផុន ជាសមាជិកក្រុមប្រឹក្សាខេត្ត

១១- ឯកឧត្តម ផៃ សេងហួត ជាសមាជិកក្រុមប្រឹក្សាខេត្ត

១២- ឯកឧត្តម ឈឹម អមរ៉ា ជាសមាជិកក្រុមប្រឹក្សាខេត្ត

១៣- ឯកឧត្តម ព្រាប ជ្រៀង ជាសមាជិកក្រុមប្រឹក្សាខេត្ត

១៤- ឯកឧត្តម នូ សំផន ជាសមាជិកក្រុមប្រឹក្សាខេត្ត

១៥- ឯកឧត្តម ខួន ឆៅសេង ជាសមាជិកក្រុមប្រឹក្សាខេត្ត ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាព ពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទបញ្ញត្តិ នៃ មាត្រា ២២ និង មាត្រា ២៣ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៩ល.០៩០៥.៥៩៨

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៥៤៣ ធ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃឹម ជិនកេន